**រាជបណ្ឌិត្យសភាកម្ពុជា**

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## - ភាគទី៥ - វគ្គទី១

អត្ថបទចងក្រងដោយៈ លោកស្រី ស៊ិន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



ទស្សនកិច្ចរបស់លោកសេនាប្រមុខសុព មកកាន់ទីក្រុងភ្នំពេញ ឆ្នាំ១៩២១[1]

[1] http://belleindochine.free.fr/CambodgeVoyages.htm

នៅក្នុងអត្ថបទភាគទី៥នេះ យើងនឹងបង្ហាញអំពីពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ ដែលបានប្រព្រឹត្តទៅនៅក្រុងភ្នំពេញ រយៈពេល៣ថ្ងៃ គឺពីថ្ងៃសុក្រទី២៧ ខែកុម្ភៈ ដល់ថ្ងៃអាទិត្យទី១ ខែមីនា ឆ្នាំ១៩២៥។

នៅក្នុងកម្មវិធីថ្ងៃសុក្រទី២៧ ខែកុម្ភៈ មានពិធីជប់លៀងជូនអតីតយុទ្ធជនចាប់ពីម៉ោង៨យប់ និងពិធីរាំកម្សាន្តនៅក្នុងសាលបុណ្យនៃសាលាក្រុងភ្នំពេញ ចាប់ពីម៉ោង១០:៣០នាទីយប់។

នៅក្នុងកម្មវិធីថ្ងៃសៅរ៍ទី២៨ ខែកុម្ភៈ មានក្បួនដង្ហែកងទ័ពចាប់ពីម៉ោង៧ព្រឹក និងការសម្ពោធ «ផ្ទាំងរំឭក»(Plaque commémorative) អំពីការស្នាក់នៅក្នុងសាលាក្រុងភ្នំពេញនៃលោកសេនាប្រមុខសុព (Maréchal Joffre) កាលពីខែធ្នូ ឆ្នាំ១៩២១។

កម្មវិធីថ្ងៃអាទិត្យទី១ ខែមីនាឆ្នាំ១៩២៥ គឺពិធីសម្ពោធ វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ ដែលនឹងបង្ហាញនៅពេលក្រោយ។

គួរបញ្ជាក់ថា លោកសេនាប្រមុខJoffre ជាអគ្គបញ្ជាការកងទ័ពបារាំង។ ពិធីបុណ្យកតញ្ញូរំឭកដល់លោកសុពនេះត្រូវបានរៀបចំឡើងមុនពិធីបុណ្យឆ្លងវិមាន១ថ្ងៃ ដើម្បីរំឭកអំពីវីរភាពរបស់លោកដែលទទួលបានជ័យជម្នះនៅក្នុងចម្បាំងជាមួយប្រទេសអាល្លឺម៉ង់ កាលពីសង្គ្រាមលោកលើកទី១(ឆ្នាំ១៩១៤-១៩១៨)។

## ៥.១-ពិធីសម្ពោធផ្ទាំងរំឭកអំពីការស្នាក់នៅក្រុងភ្នំពេញនៃលោកសេនាប្រមុខសុព(ឆ្នាំ១៩២១)

### ក-ការរំឭកអំពីការស្នាក់នៅនៃលោកសេនាប្រមុខសុព

បណ្ណសារស្ដីពី«បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨) នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥» មានខ្លឹមសារដើម និងសេចក្ដីសម្រួលមួយចំនួនដូចតទៅ[2]៖

តាំងតែពីចូលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩២៥វេលាណា ក្រុងភ្នំពេញហាក់ដូចបានចូលក្នុងពិធីបុណ្យទៅហើយ។ គេឃើញមានដោតទង់ជ័យជាក្រសោមជាច្រើននៅផ្លូវតូចធំ និងមុខផ្ទះ ហើយបក់ទង្គិចគ្នាឮសូរតាមខ្យល់។ នៅផ្លូវក្នុងក្រុងនោះគេសម្គាល់ឃើញមានមនុស្សច្រួលច្របរជាច្រើន ក្នុងខណៈនោះគេដឹង

[2]បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៦៣-៦៤។

ថាជិតមានធ្វើបុណ្យធំ។ ថ្ងៃនោះជាថ្ងៃមុនពិធីបុណ្យ១ថ្ងៃ ដែលលោករេស៊ីដង់ជាន់ខ្ពស់ ត្រូវធ្វើជាអធិបតីក្នុងពិធីបុណ្យឆ្លងវិមានរំឭកដល់អ្នកអនិច្ចកម្មក្នុងសង្គ្រាមលោកលើកទី១ ជំនួសលោកអគ្គទេសាភិបាលឥណ្ឌូចិនដែលមិនបានអញ្ជើញមក ដោយជាប់ភារកិច្ចនៅទីក្រុងតុងកឹង(ក្រុងហាណូយ)។ ឯវិមានដែលត្រូវធ្វើបុណ្យឆ្លងនោះ ទើបតែនឹងធ្វើហើយជាស្រេច។

កាលសម័យដែលមានចម្បាំងធំនោះ មនុស្សគ្រប់គ្នានៅមានស្មារតីចាំទាំងអស់គ្នា។ បើមានស្មារតីចាំដូច្នេះហើយធ្វើម៉ិចក៏គង់ចាំកាល៣ឆ្នាំមុននោះ ក្រុងភ្នំពេញបានរៀបទទួលលោកសេនាប្រមុខសុព ដែលជាមេកងទ័ពមានថ្វីដៃជាប្រាកដ។ ឯការយកឈ្មោះលោកសេនាប្រមុខ មកធ្វើបុណ្យកតញ្ញូដែលសម្រេចធ្វើនៅ២៤ម៉ោងក្រោយនេះ ជាការតបគុណដោយគួរណាស់ ព្រោះក្រោយដែលមានទុក្ខធំវេទនា ពីដើមដំបូងធ្វើឱ្យអ្នកផងមានសេចក្ដីបារម្ភគ្មានសង្ឃឹមនោះ លោកសេនាប្រមុខនៅតែមានចិត្តឥតកោតញញើតដល់តិចឡើយ។ ឯសេចក្ដីដែលឥតកោតញញើតក្នុងចិត្តលោកយ៉ាងដូច្នេះនេះ ក៏នាំបណ្ដាលឱ្យមានជ័យជម្នះដែលហាក់ដូចជាឃ្លាតឆ្ងាយទៅហើយនោះឱ្យបានមកក្នុងកណ្ដាប់ដៃកងទ័ពយើងវិញ។

គ្មានឱកាសណាល្អជាជាងនេះយកមកធ្វើបុណ្យរំឭកពីលោកសេនាប្រមុខសុព ដែលអញ្ជើញមកនេះទេ។ ម្យ៉ាងទៀតដោយលោកបានមកស្នាក់នៅក្នុងផ្ទះរេស៊ីដង់ក្រុមមឿង[3]ចំនួន៣ថ្ងៃនោះ រាជការក្រុងភ្នំពេញ បានធ្វើ«ផ្ទាំងរំឭក»បិទនៅផ្ទះរាជការក្រុមមឿង(សាលាក្រុងភ្នំពេញ)ទុកជាទីនឹកក្នុងខណៈដែលលោកបានអញ្ជើញមក។

ឯពិធីបុណ្យនេះបានធ្វើជាស្រេចនៅថ្ងៃទី២៨ ខែកុម្ភៈ វេលាម៉ោង៩ព្រឹក នៅទីរាជការក្រុមមឿងក្នុងបន្ទប់ធំនៅជុំវិញ[4] មុងស៊ីយ៉ឺរ ឡឺរេស៊ីដង់មែរ[5] និងក្រុមកុមីស៊ីយ៉ុងរាជការក្រុមមឿង[6] មានលោក សាសសាំង ជាអាំងស្ប៉ិកទ័រក្រសួងប៉ូលីទិក[7] ជាអ្នកតំណាងលោកឡឺរេស៊ីដង់ជាន់ខ្ពស់ ដែលរវល់ពុំបានមក, មានសម្ដេចក្រុមព្រះ ៗ កែវហ្វាមុនីវង្សជាព្រះតំណាងព្រះករុណា, មានភ្នាក់ងារក្នុងរាជការនិងក្នុង ជំនួញ, មានពួកនាយទាហាន, មានសេនាបតី និងនាម៉ឺនធំៗ ក្នុងរាជការព្រះករុណា។ នៅមុខពពួកក្រុម ទាំងនេះ

---

[3]រេស៊ីដង់ក្រុមមឿង (Résidence-Mairie) គឺសាលាក្រុងភ្នំពេញ។

[4]គឺនៅក្រោមអធិបតីភាព។

[5]មុងស៊ីយ៉ឺរ ឡឺរេស៊ីដង់មែរ(Monsieur le Résident-Maire) គឺលោកចៅហ្វាយក្រុង(ភ្នំពេញ)។

[6]កុមីស៊ីយ៉ុងរាជការក្រុមមឿង(Commission municipale) គឺគណៈកម្មការក្រុង។

[7]អាំងស្ប៉ិកទ័រក្រសួងប៉ូលីទិក (Inspecteur politique) គឺអធិការខាងនយោបាយ។

មុងស៊ីយ៉ើរប៉ាទ្រី ជារេស៊ីដង្តក្រុមមឿង(ចៅហ្វាយក្រុង) បានសូត្រសេចក្ដីអធិប្បាយ ដូចមាន ខាងក្រោមនេះ។

**ខ-សុន្ទរកថារបស់លោកចៅហ្វាយក្រុងភ្នំពេញ[8]**

*សូមអស់លោក អស់អ្នកជ្រាប។*

*អស់លោកអ្នករាល់គ្នាក៏នៅចាំនៅឡើយ ពីលោកមេទ័ពធំបង្អស់ឈ្មោះសុព ដែលរាជការគូវែរណើម៉ង្គបារាំងសែស[9] បានចាត់ឱ្យមកប្រទេសខាងកើតបំផុត[10] ហើយលោកបានអញ្ជើញមកក្រុងភ្នំពេញ នៅក្នុងខែធ្នូ ឆ្នាំ១៩២១។*

*កាលដែលលោកអញ្ជើញមកក្រុងភ្នំពេញនោះ លោកសេនាប្រមុខសុពបានសំណាក់នៅទីរាជការក្រុមមឿង(សាលាក្រុង)។ កាលនោះដួនជាលោកឌូក្វាំង(Ducoing)ជាងធ្វាក់ក៏នៅក្រុងភ្នំពេញដែរ កំពុងតែរិះគិតធ្វាក់វិមាន១ ទុកនៅស្រុកខ្មែរ ជាកិត្តិយសដល់អ្នកដែលបាត់បង់ក្នុងសឹកសង្គ្រាមធំ លោករេស៊ីដង់ជាន់ខ្ពស់បូដូវាំង (Baudoin) ឃើញថាវេលានោះជាវេលាស្រួលល្អ ក៏យករូបដែលលោក ឌូក្វាំងជាជាងប៉ិនធ្វាក់ឯក បានធ្វើមួយយ៉ាងតូចជាគំរូទៅពិគ្រោះនិងលោកសេនាប្រមុខសុព។ លោកសេនាប្រមុខបានឃើញរូបវិមាននោះល្អឆើត ហើយលោកក៏គាប់ចិត្ត និងគំនិតដ៏ប្រសើរដែលជាងយល់ហើយត្រូវចិត្តនឹងរូបនោះ ដែលជាងបានធ្វើសមល្អណាស់ ក៏យល់ឱ្យធ្វើដូចទាំងអស់ ឥតមានយល់ទាស់ត្រង់ណាឡើយ។ រាជការក្រុងភ្នំពេញ មានចិត្តចង់រំឭកពីលោកសេនាប្រមុខសុព ដែលបានអញ្ជើញមកក្រុងភ្នំពេញកាលពីឆ្នាំ១៩២១។ នៅក្នុងឱកាសបុណ្យឆ្លងវិមាននេះ រាជការក្រុងភ្នំពេញបានសម្រេចឱ្យបោះផ្ទាំង១បន្ទះ ក្នុងបន្ទប់កិត្តិយសនៅក្នុងសាលាក្រុង ជាសេចក្ដីរំឭកដល់លោកសេនាប្រមុខដែលបានអញ្ជើញមកទីក្រុងនេះ។*

(សូមរង់ចាំអានភាគបន្ត...)

---

[8]បុន្យឆ្លងវិមានដែរសាងក្នុងក្រុងភ័ម្ពជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៦៤-៦៥។

[9]គូវែរណើម៉ង្គបារាំងសែស (Gouvernement français) គឺរដ្ឋាភិបាលបារាំង។

[10]ប្រទេសខាងកើតបំផុត គឺចុងបូព៌ាប្រទេស។